ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌

លេខ: ៧ សស

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការដាក់ឱ្យដំណើរការសាលាដំបូងខេត្តកែប និងអយ្យការអមសាលាដំបូងខេត្តកែប

ក្រសួងយុត្តិធម៌មានកិត្តិយសសូមជម្រាបជូនដល់សាធារណជនឱ្យបានជ្រាបថា យោងតាមព្រះរាជក្រឹត្យលេខ នស/រកត/០៤២១/៣៤៥ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២១, សាលាដំបូងខេត្តកែប និងអយ្យការអមសាលាដំបូងខេត្តកែប នឹងត្រូវប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១ ខាងមុខនេះ។ យោងតាមច្បាប់ស្តីពីការរៀបចំអង្គការតុលាការ សាលាដំបូងជាសាលាជម្រះក្តីថ្នាក់ទីមួយ ដែលត្រូវបង្កើតឱ្យមាននៅរាជធានីភ្នំពេញ និងនៅគ្រប់ខេត្តនៃព្រះរាជាណាចក្រកម្ពុជា។ សាលាដំបូងខេត្តកែប និងអយ្យការអមសាលាដំបូងខេត្តកែប គឺជាសាលាជម្រះក្តីថ្នាក់ទីមួយនៅតាមខេត្តចុងក្រោយគេ ដែលត្រូវបានប្រកាសដាក់ឱ្យដំណើរការ។

ពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវសាលាដំបូងខេត្តកែប និងអយ្យការអមសាលាដំបូងខេត្តកែប នឹងប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលមានអាសយដ្ឋាននៅទីតាំងដួលជាបណ្តោះអាសន្ន ស្ថិតនៅដីឡូត៍លេខ៤០៦ ផ្លូវជាតិលេខ៣៣A ភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប។

អាស្រ័យហេតុនេះ សូមសាធារណជនទាំងអស់ មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃអង្គារ ១៥កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១
ក្រសួងយុត្តិធម៌